សេចក្តីណែនាំពីការលើកលែងភាពលំបាកលំបិន

ក្នុងស្ថានភាពជាក់លាក់មួយចំនួន តម្លៃវិក្កយបត្រគិលានសង្គ្រោះអាចត្រូវបានលើកលែងអាស្រ័យលើឯកសារសម្អាងហិរញ្ញវត្ថុ និងការអនុម័តរបស់មេធាវីក្រុង។ សេចក្តីណែនាំស្តីពីរបៀបបំពេញទម្រង់បែបបទលើកលែងភាពលំបាកលំបិន មានដូចខាងក្រោម។

1. សូមបំពេញទម្រង់បែបបទនៃសេចក្តីប្រកាសភាពលំបាកលំបិន ដោយវាយបញ្ចូលព័ត៌មានរបស់លោកអ្នក ឬ ព្រីនទម្រង់បែបបទ ហើយសរសេរព័ត៌មានរបស់លោកអ្នក។
2. លើទម្រង់បែបបទដែលបានបង្ហាញ សូមបញ្ចូល "ឈ្មោះរបស់អ្នកជំងឺ"។
3. ក្នុងតួសេចក្តីនៃទម្រង់បែបបទ សូមរៀបរាប់ពីមូលហេតុទាំងអស់ដែលលោកអ្នកមិនអាចបង់ប្រាក់ ដែលលោកអ្នកជំពាក់ទីក្រុងឡុងប៊ិច (City of Long Beach)។ សូមផ្តល់ព័ត៌មានលម្អិតឱ្យបានច្រើនតាមតែអាចធ្វើបាន ដោយពន្យល់ពីមូលហេតុដែលលោកអ្នកមិនអាចបង់ទឹកប្រាក់ដែលបានជំពាក់ ដូចជា ការបាត់បង់ការងារ ស្ថានភាពសុខភាព ឬ បញ្ហាស្រដៀងគ្នា។ លើសពីនេះ សូមប្រាប់ពីចំនួនទឹកប្រាក់ដែលលោកអ្នកអាចបង់ បើមាន។
4. នៅផ្នែកខាងក្រោមនៃទម្រង់បែបបទដែលបានបង្ហាញ សូមបញ្ចូល "កាលបរិច្ឆេទ" នៅពេលទម្រង់បែបបទត្រូវបានបំពេញ។ លើសពីនេះ សូមបញ្ចូលឈ្មោះ "ទីក្រុង" ដែលទម្រង់បែបបទត្រូវបានបំពេញ។
5. សូមបញ្ចូល "លេខដំណើរការ" ក្នុងចន្លោះដែលបានផ្តល់ជូន។ លេខដំណើរការស្ថិតនៅលើវិក្កយបត្រ ខាងក្រោមឈ្មោះអ្នកជំងឺ នៅផ្នែកឆ្វេងដៃខាងលើនៃវិក្កយបត្រ។
6. សូមចុះហត្ថលេខាលើសេចក្តីប្រកាសនេះ ក្នុងចន្លោះដែលបានផ្តល់។ ហត្ថលេខាអាចជារបស់អ្នកជំងឺ អ្នកធានា ឬ ឪពុក/ម្តាយ ឬ អាណាព្យាបាលរបស់អ្នកជំងឺ។

ប្រគល់ត្រឡប់នូវឯកសារខាងក្រោមទៅទីក្រុងឡុងប៊ិចវិញ (City of Long Beach):

1. ទម្រង់បែបបទនៃសេចក្តីប្រកាសភាពលំបាកលំបិនដែលបានបំពេញរួច
2. សេចក្តីចម្លងមួយច្បាប់ នៃទម្រង់បែបបទ IRS W2 ចុងក្រោយរបស់លោកអ្នក (ទម្រង់បែបបទពន្ធដារសហព័ន្ធរបស់សហរដ្ឋអាមេរិក ដែលបានចេញដោយនិយោជក និងមានបង្ហាញពីចំណូលរបស់និយោជិក)។
3. សេចក្តីចម្លងមួយច្បាប់ នៃរបាយការណ៍ធនាគារថ្មីបំផុតរបស់លោកអ្នក។

ប្រគល់ត្រឡប់នូវឯកសារដែលបានតម្រូវទៅកាន់ទីក្រុង (City) វិញ តាមរយៈអាសយដ្ឋានអ៊ីម៉ែល AmbulanceBilling@LongBeach.gov ឬ ផ្ញើសំបុត្រទៅទីក្រុងឡុងប៊ិច (City of Long Beach) ជូនចំពោះ ៖ Ambulance Billing, P.O. Box 22600, Long Beach, CA 90801។

ប្រសិនបើលោកអ្នកមានសំណួរ សូមទាក់ទងយើងខ្ញុំ តាមរយ:

- ទូរស័ព្ទលេខ (562) 570-7600 ជ្រើសជម្រើស #4
- ផ្ញើអ៊ីម៉ែលនូវសំណួរផ្សេងៗ ទៅ AmbulanceBilling@LongBeach.gov ឬ
- ទៅកាន់ផ្នែកវិក្កយបត្រគិលានសង្គ្រោះនៅសាលាក្រុង តាមអាសយដ្ឋាន 333 West Ocean Blvd., Lobby Level, Long Beach, California, ចាប់ពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ ម៉ោង 7:30 ព្រឹក ដល់ម៉ោង 4:30 ល្ងាច។